ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារជូនពរ

**សូមគោរពជូន**

**សម្តេចតេជោបុលសេនាគក្ក សាយ ឈុំ ប្រធានព្រឹទ្ធសភា**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**សម្តេចតេជោបុលសេនាគក្ក ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្តេចតេជោបុលសេនាគក្ក** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រឹទ្ធសភាដែលជាស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវលទ្ធផលត្រចះត្រចង់ថ្មីៗថែមទៀត។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងស្មារតីភក្តីយ៉ាងជ្រាលជ្រៅបំផុត មិនអាចបំភ្លេចបានចំពោះសកម្មភាពស្នេហាជាតិប្រកបដោយគំរូវីរភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោបុលសេនាគក្ក** តែងតែបានយកអស់កម្លាំងកាយចិត្ត និងរាល់បទពិសោធន៍ក្នុងការដឹកនាំព្រឹទ្ធសភា ឱ្យក្លាយជាស្ថាប័ននីតិប្បញ្ញត្តិមួយប្រកបដោយសក្តានុពល ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅរកនីតិរដ្ឋមួយដែលជាមូលដ្ឋានគ្រឹះធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿងស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមលើកហត្ថបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្តេចតេជោបុលសេនាគក្ក** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចតេជោបុលសេនាគក្ក សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១២កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០១៩
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកឌឺហ្គោល សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤: generalsec@mod.gov.kh